KB PRASAC Bank

# ពាក្យស្នើសុំផ្ទេរប្រាក់អន្តរជាតិ
# INTERNATIONAL FUND TRANSFER FORM

កាលបរិច្ឆេទ / Date........../........../..........

សាខា / Branch ..........

លេខយោងប្រតិបត្តិការ/Transaction Ref. Nº ..........

## I. ព័ត៌មានអ្នកស្នើសុំ / Applicant Information

ឈ្មោះគណនី/Account Name ..........

លេខគណនី/Account Number ..........

លេខទូរស័ព្ទ/Phone Number ..........

អាសយដ្ឋាន/Address ..........

..........

## II. ចំនួនទឹកប្រាក់ក្នុងការផ្ទេរ / Amount of Transfer

រូបិយប័ណ្ណ/Currency ..........

ចំនួនទឹកប្រាក់ជាលេខ/Amount in figure ..........

ចំនួនទឹកប្រាក់ជាអក្សរ/Amount in words ..........

..........

..........

## III. ព័ត៌មានធនាគារអន្តរការី (ប្រសិនបើមាន) / Intermediary bank (optional)

ឈ្មោះធនាគារអន្តរការី/Name of Intermediary's bank ..........

..........

លេខ SWIFT/Other Codes ..........

អាសយដ្ឋាន/Address ..........

..........

..........

## IV. ព័ត៌មានធនាគារទទួលផល / Beneficiary's bank details

ឈ្មោះធនាគារទទួលផល/Name of beneficiary's bank ..........

..........

លេខ SWIFT/Other Codes ..........

អាសយដ្ឋានធនាគារ/Bank Address ..........

..........

..........

## V. ព័ត៌មានអ្នកទទួលផល / Beneficiary Information

ឈ្មោះគណនី/Account Name ..........

លេខគណនី/Account Number/IBAN ..........

លេខទូរស័ព្ទ/Phone Number ..........

អាសយដ្ឋាន/Address ..........

..........

## VI. គោលបំណងនៃការផ្ទេរប្រាក់ / Purpose of Transfer

**គោលបំណងផ្ទាល់ខ្លួន/Personal Purpose**

☐ ការប្រើប្រាស់ផ្ទាល់ខ្លួន/Personal Use ☐ ផ្ញើឱ្យបងប្អូន/Send to a relative

☐ ផ្សេងៗ/Others ..........

..........

**គោលបំណងអាជីវកម្ម/Business Purpose**

☐ ទូទាត់ថ្លៃទំនិញ/វិក្កយបត្រ/Pay for goods/invoice ☐ ទូទាត់បំណុល/Loan Repayment

☐ ទូទាត់ចំណាយប្រតិបត្តិការ/Operation Expense ☐ ផ្សេងៗ/Others ..........

..........

សារទៅអ្នកទទួលផល/Message to Beneficiary ..........

## VII. ទំនាក់ទំនងហិរញ្ញវត្ថុ (សូមមើលលក្ខខណ្ឌទំព័រខាងក្រោយ) / Financial Relationship (Please see the back page)

☐ មាន (R) ☐ គ្មាន (N) ☐ មិនដឹង (DN)

| ព័ត៌មានលម្អិតប្រតិបត្តិការ / Transaction Details | |
|---|---|
| CHARGE | ☐ SHA ☐ BEN ☐ OUR |
| Amount | |
| Exchange rate | |
| Equivalent | |
| Commission | |
| Cable Charge | |
| OUR Charge | |
| Others | |
| Total | |

### សម្រាប់អតិថិជន / For Customer Use only

បានឯកភាពតាមលក្ខខណ្ឌសេវាផ្ទេរប្រាក់អន្តរជាតិដូចបានចែងនៅផ្នែកខាងក្រោយ

Confirmed and agreed with all Terms & Conditions at the backside

ហត្ថលេខាអតិថិជន/Client's Signature

### សម្រាប់សាខា / Branch Use only

☐ Customer/Agent Verified ☐ Signature Verified

☐ Document Checked ☐ AML checked

ចុះបញ្ជីដោយ/Posted by អនុម័តដោយ/Approved by

### សម្រាប់ការិយាល័យកណ្តាល / Head Office Use Only

☐ AML Checked ..........

☐ Transaction Ref. Nº ..........

ចុះបញ្ជីដោយ/Posted by ត្រួតពិនិត្យដោយ/Verified by អនុម័តដោយ/Approved by

# លក្ខខណ្ឌនៃការប្រើប្រាស់សេវាផ្ទេរប្រាក់អន្តរជាតិ

## I. លក្ខខណ្ឌប្រើប្រាស់

លក្ខខណ្ឌនៃការប្រើប្រាស់ **សេវាផ្ទេរប្រាក់អន្តរជាតិ** គឺជាកិច្ចព្រមព្រៀងរវាង **អតិថិជន** និង **ធនាគារ ខេប៊ីប្រាសាក់ ម.ក** ពាក់ព័ន្ធនឹងការស្នើសុំធ្វើប្រតិបត្តិការសេវាផ្ទេរប្រាក់អន្តរជាតិ តាមរយៈសាខា ឬ សេវាខេប៊ីប្រាសាក់ខបភើរេត ឬ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។ ក្នុងករណី លោក-លោកស្រី បានព្រមព្រៀងទៅលើលក្ខខណ្ឌប្រើប្រាស់ នៃប្រតិបត្តិការសេវាផ្ទេរប្រាក់អន្តរជាតិ នោះមានន័យថា លោក-លោកស្រី បានអាន បានយល់ និងបានព្រមព្រៀងទទួលយកនូវរាល់លក្ខខណ្ឌប្រើប្រាស់នៃប្រតិបត្តិការសេវាផ្ទេរប្រាក់អន្តរជាតិ។

ករណី លោក-លោកស្រី មានចម្ងល់ទាក់ទងនឹងចំណុចណាមួយដែលមានចែងនៅក្នុងលក្ខខណ្ឌប្រើប្រាស់នេះ លោក-លោកស្រីអាចស្វែងរកការពន្យល់បន្ថែមពីបុគ្គលិកខេប៊ីប្រាសាក់ដោយផ្ទាល់នៅគ្រប់សាខាខេប៊ីប្រាសាក់ទាំងអស់ ឬ តាមរយៈទូរស័ព្ទទៅកាន់លេខ ០២៣/០៨៦ ៩៩៩ ៩១១ បានគ្រប់ពេលវេលា។

សូម លោកលោកស្រី អានលក្ខខណ្ឌខាងក្រោមដោយប្រុងប្រយ័ត្ន ហើយធ្វើការបញ្ជាក់ឡើងវិញ ករណីមានចម្ងល់មុនសម្រេចប្រើប្រាស់សេវាផ្ទេរប្រាក់អន្តរជាតិ។

## II. និយមន័យ

ពាក្យគន្លឹះប្រើប្រាស់នៅក្នុងលក្ខខណ្ឌនៃការប្រើប្រាស់សេវាផ្ទេរប្រាក់អន្តរជាតិ៖

- **«លោក លោកស្រី»** ៖ សំដៅដល់ អតិថិជន ដែលបានស្នើសុំ ឬ ប្រើប្រាស់សេវាផ្ទេរប្រាក់អន្តរជាតិរបស់**ខេប៊ីប្រាសាក់**
- **«លក្ខខណ្ឌប្រើប្រាស់»** ៖ សំដៅដល់ «លក្ខខណ្ឌនៃការប្រើប្រាស់សេវាផ្ទេរប្រាក់អន្តរជាតិ»
- **«ធនាគារ»** ឬ **«ខេប៊ីប្រាសាក់»** ៖ សំដៅដល់ **ធនាគារ ខេប៊ីប្រាសាក់ ម.ក**
- **«សេវាផ្ទេរប្រាក់អន្តរជាតិ»** ៖ សំដៅដល់ការផ្ទេរប្រាក់ចេញទៅក្រៅប្រទេស និងទទួលប្រាក់ផ្ទេរចូលពីក្រៅប្រទេសរវាងធនាគារ ខេប៊ីប្រាសាក់ និងធនាគារនៅក្រៅប្រទេសផ្សេងទៀតតាមរយៈប្រព័ន្ធផ្ទេរប្រាក់អេឡិកត្រូនិក (SWIFT) ។
- **«ទំនាក់ទំនងហិរញ្ញវត្ថុ»** ៖ សំដៅដល់ទំនាក់ទំនងរវាង លោក-លោកស្រី និងក្រុមហ៊ុនសហគ្រាស របស់លោក-លោកស្រី ឬ ក្រុមហ៊ុនផ្សេងៗទៀត ដែលជាសម្ព័ន្ធញាតិដោយលោក-លោកស្រីអាចកាន់កាប់ភាគហ៊ុនដោយផ្ទាល់ ឬ ដោយប្រយោល។
- **«មានទំនាក់ទំនង»** ឬ **«មាន»** ៖ សំដៅដល់ការវិនិយោគរបស់ប្រតិបត្តិករជានិវាសនជន ឬ អនិវាសនជនជាមួយប្រតិបត្តិករជានិវាសនជន ឬ អនិវាសនជនផ្សេងទៀត ដែលមានភាគហ៊ុន ១០% ឬ ច្រើនជាង១០% ។
- **«គ្មានទំនាក់ទំនង»** ឬ **«គ្មាន»** ៖ សំដៅដល់ការវិនិយោគរបស់ប្រតិបត្តិករជានិវាសនជន ឬ អនិវាសនជនជាមួយប្រតិបត្តិករជានិវាសនជន ឬ អនិវាសនជនផ្សេងទៀត ដែលមានភាគហ៊ុនតិចជាង១០% ។
- **«មិនដឹងពីទំនាក់ទំនង»** ឬ **«មិនដឹង»** ៖ សំដៅដល់ការមិនដឹងអំពីទំនាក់ទំនងហិរញ្ញវត្ថុណាមួយ។

## III. ការទទួលខុសត្រូវរបស់អតិថិជន

1. លោក-លោកស្រី ត្រូវធានាថារាល់ព័ត៌មានទាំងអស់ដែលបានផ្តល់ឱ្យ **ខេប៊ីប្រាសាក់** សម្រាប់ការស្នើសុំធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងសេវាផ្ទេរប្រាក់អន្តរជាតិ គឺជាព័ត៌មានត្រឹមត្រូវ និងថ្មីបំផុត។
2. លោក-លោកស្រី ត្រូវពិនិត្យគ្រប់ព័ត៌មាននៃការស្នើសុំធ្វើប្រតិបត្តិការសេវាផ្ទេរប្រាក់អន្តរជាតិ និងកម្រៃសេវាពាក់ព័ន្ធឱ្យបានច្បាស់លាស់មុននឹងសម្រេចធ្វើប្រតិបត្តិការផ្ទេរប្រាក់អន្តរជាតិ។
3. លោក-លោកស្រី ផ្តល់សិទ្ធិឱ្យខេប៊ីប្រាសាក់ ធ្វើការដកប្រាក់ចេញពីគណនីរបស់លោក-លោកស្រី រួមទាំងទឹកប្រាក់ផ្ទេរ និងកម្រៃសេវាពាក់ព័ន្ធលើការស្នើសុំប្រើប្រាស់សេវាផ្ទេរប្រាក់អន្តរជាតិ។
4. លោក-លោកស្រី យល់ព្រមថា **ខេប៊ីប្រាសាក់** នឹងអនុវត្តតាមអត្រាប្តូរប្រាក់របស់ធនាគារ ដើម្បីធ្វើការផ្ទេរប្រាក់អន្តរជាតិជារូបិយបណ្ណ័បរទេស។
5. លោក-លោកស្រីត្រូវទទួលខុសត្រូវក្នុងការផ្តល់នូវព័ត៌មាន និង/ឬ ឯកសារបន្ថែមពាក់ព័ន្ធនឹងការផ្ទេរប្រាក់អន្តរជាតិ ប្រសិនបើមានការស្នើសុំ និង/ឬ តម្រូវដោយធនាគារ ឬ ច្បាប់។
6. លោក-លោកស្រី យល់ព្រមថា សំណើផ្ទេរប្រាក់អន្តរជាតិជាលាយលក្ខណ៍អក្សរដែលបានស្នើសុំនៅតាមសាខា ឬ តាមរយៈសេវាខេប៊ីប្រាសាក់ខបភើរេត ឬ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល នឹងត្រូវបានដាក់ស្នើសុំទៅកាន់ខេប៊ីប្រាសាក់ដើម្បីពិនិត្យ និងធ្វើប្រតិបត្តិការ។ ខេប៊ីប្រាសាក់អាចនឹងធ្វើការទាក់ទងទៅលោកលោកស្រីសម្រាប់ការសាកសួរព័ត៌មាន និង/ឬ ស្នើសុំឯកសារបន្ថែម (ករណីចាំបាច់) ។
7. លោក-លោកស្រី យល់ព្រមទទួលខុសត្រូវទាំងស្រុងចំពោះច្បាប់ជាតិ និងអន្តរជាតិ ហើយធានាថារាល់សកម្មភាពនៃការធ្វើប្រតិបត្តិការសេវាផ្ទេរប្រាក់អន្តរជាតិ ដែលធ្វើឡើងក្នុងនាមខ្លួនឯងផ្ទាល់ និង/ឬ សាច់ញាតិ នឹងស្ថិតនៅក្រោមលក្ខខណ្ឌនេះ។

## IV. ការទទួលខុសត្រូវរបស់ខេប៊ីប្រាសាក់

1. **ខេប៊ីប្រាសាក់** នឹងទទួលធ្វើប្រតិបត្តិការផ្ទេរប្រាក់អន្តរជាតិ ទៅតាមព័ត៌មានដែល លោក-លោកស្រី បានស្នើសុំ និងផ្តល់ឱ្យតែប៉ុណ្ណោះ។
2. **ខេប៊ីប្រាសាក់** នឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ និងការចំណាយផ្សេងៗទៀត ដែលបណ្តាលមកពីការផ្តល់ព័ត៌មានមិនត្រឹមត្រូវ មិនគ្រប់គ្រាន់ និងមិនច្បាស់លាស់ ឬ ការកើតឡើងដោយសារកំហុស ការធ្វេសប្រហែស ការពន្យារពេល ឬ គ្មានលទ្ធភាពទូទាត់របស់ធនាគារដៃគូ ឬ ការកើតឡើងដោយបុព្វហេតុ ឬ ហេតុផលផ្សេងៗដែលហួសពីការគ្រប់គ្រងរបស់ធនាគារ និង ធនាគារដៃគូ ណាមួយឡើយ។
3. **ខេប៊ីប្រាសាក់** មានសិទ្ធិជ្រើសរើសធនាគារដៃគូ ដើម្បីឱ្យដំណើរការនៃការស្នើសុំផ្ទេរប្រាក់អន្តរជាតិរបស់លោក-លោកស្រី មានប្រសិទ្ធភាពខ្ពស់។ ធនាគារដៃគូអាចនឹងគិតកម្រៃសេវា លើការទូទាត់ប្រតិបត្តិការបន្ត ដែលកម្រៃសេវានេះអាចត្រូវបានដកចេញពីមូលនិធិដែលត្រូវទូទាត់ទៅឱ្យអ្នកទទួលផល។ ក្នុងករណីនេះ អ្នកទទួលផលនឹងទទួលបានទឹកប្រាក់ផ្ទេរតិចជាងសមតុល្យដែលបានផ្ទេរខាងដើម។ ប្រសិនបើកម្រៃសេវានោះ ត្រូវបានទូទាត់ដោយ **ខេប៊ីប្រាសាក់** នោះ លោក-លោកស្រី ដែលជាអ្នកផ្ទេរ អនុញ្ញាតឱ្យ **ខេប៊ីប្រាសាក់** ទូទាត់ចេញពីគណនី របស់លោក-លោកស្រី។
4. ខេប៊ីប្រាសាក់ អាចនឹងព្យួរ ពន្យារ ឬ បដិសេធ សំណើរបស់ លោក-លោកស្រី ក្នុងករណី ខេប៊ីប្រាសាក់ ពិនិត្យឃើញថា លោក-លោកស្រី មិនបានបំពេញតាមលក្ខខណ្ឌតម្រូវ ឬ មិនមានឯកសារ ឬ មិនមានព័ត៌មានគាំទ្រគ្រប់គ្រាន់លើសំណើផ្ទេរប្រាក់របស់ខ្លួន។
5. **ខេប៊ីប្រាសាក់** រក្សាសិទ្ធិក្នុងការកែប្រែនូវកម្រៃសេវា ការកំណត់អំពីទំហំទឹកប្រាក់នៃការធ្វើប្រតិបត្តិការ និងលក្ខខណ្ឌចាំបាច់ផ្សេងទៀត ចំពោះការប្រើប្រាស់សេវាផ្ទេរប្រាក់អន្តរជាតិ ដោយ **ខេប៊ីប្រាសាក់** នឹងធ្វើការជូនដំណឹងឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។
6. ខេប៊ីប្រាសាក់ មិនទទួលខុសត្រូវលើពន្ធនានា កាតព្វកិច្ច និងការចំណាយផ្សេងៗដែលនឹងអាចកើតមាននៅប្រទេសដទៃពាក់ព័ន្ធនឹងការផ្ទេរប្រាក់នេះឡើយ។

## V. សំណើសុំពាក់ព័ន្ធប្រតិបត្តិការផ្ទេរប្រាក់អន្តរជាតិ

1. លោក-លោកស្រី ត្រូវធ្វើការស្នើសុំមក **ខេប៊ីប្រាសាក់** សម្រាប់រាល់សំណើពាក់ព័ន្ធនឹងប្រតិបត្តិការផ្ទេរប្រាក់អន្តរជាតិរួមទាំងសំណើកែប្រែព័ត៌មាន ការស៊ើបអង្កេត សំណើពន្យារពេលទូទាត់ ឬ ការលុបចោលការទូទាត់ជាដើម។
2. លោក-លោកស្រី យល់ព្រមក្នុងការទូទាត់សំណងជូន **ខេប៊ីប្រាសាក់** យោងទៅតាមលក្ខខណ្ឌ **«សំណងនៃការខូចខាត»**។
3. លោក-លោកស្រី យល់ព្រមឱ្យ **ខេប៊ីប្រាសាក់** កាត់កងទឹកប្រាក់ដែលមាននៅក្នុងគណនីរបស់ លោក-លោកស្រីដើម្បីទូទាត់នូវរាល់សំណង ដែលបានរៀបរាប់ខាងលើទៅតាមស្ថានភាពជាក់ស្តែង។
4. ក្នុងករណីការផ្ទេរប្រាក់អន្តរជាតិត្រូវបានបដិសេធ ឬ លុបចោល ឬ បង្វិលត្រលប់ ខេប៊ីប្រាសាក់ នឹងទូទាត់ប្រាក់ផ្ទេរត្រលប់ (បន្ទាប់ពីទូទាត់កម្រៃសេវាផ្សេងៗរួចរាល់) ចូលទៅក្នុងគណនី លោក-លោកស្រី វិញ នៅពេល **ខេប៊ីប្រាសាក់**បានទទួលទឹកប្រាក់ត្រលប់ពីធនាគារដៃគូ។ ប្រសិនបើទឹកប្រាក់ត្រលប់ជារូបិយប័ណ្ណបរទេស ខុសពីរូបិយប័ណ្ណគណនីនោះ **ខេប៊ីប្រាសាក់** នឹងអនុវត្តតាមអត្រាប្តូរប្រាក់ជាក់ស្តែងរបស់ខេប៊ីប្រាសាក់នៅកាលបរិច្ឆេទនៃការទទួលទឹកប្រាក់ត្រលប់។

## VI. កម្រៃសេវាផ្ទេរប្រាក់អន្តរជាតិ

1. កម្រៃសេវាផ្ទេរប្រាក់អន្តរជាតិ និងកម្រៃសេវាពាក់ព័ន្ធផ្សេងៗទៀតត្រូវបានកំណត់ដោយ **ខេប៊ីប្រាសាក់**។
2. លោក-លោកស្រី យល់ព្រមឱ្យ **ខេប៊ីប្រាសាក់** ទូទាត់កម្រៃសេវាចេញពីគណនីរបស់លោក-លោកស្រី ដើម្បីទូទាត់កម្រៃសេវាលើការស្នើសុំផ្ទេរប្រាក់អន្តរជាតិ (រួមទាំងការស្នើសុំកែប្រែ ឬ ការលុបចោលការទូទាត់ ឬ ការស៊ើបអង្កេត) និងការចំណាយផ្សេងៗទៀតពីខាងធនាគារដៃគូ។

## VII. ការរក្សាការសម្ងាត់

1. **ខេប៊ីប្រាសាក់** នឹងមិនបង្ហាញព័ត៌មានផ្ទាល់ខ្លួន ឬ ព័ត៌មានគណនី ឬ ប្រតិបត្តិការគណនីរបស់លោក-លោកស្រី ទៅឱ្យភាគីទីបីឡើយ លើកលែងតែករណីដូចខាងក្រោម៖
   - **ខេប៊ីប្រាសាក់** មានតម្រូវការព័ត៌មានសម្រាប់រៀបចំរបាយការណ៍ ឬ សកម្មភាពពាក់ព័ន្ធផ្សេងទៀតតម្រូវតាមច្បាប់ជាតិ និងអន្តរជាតិ។
   - មានដីកាពីតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចក្នុងគោលបំណងស៊ើបអង្កេត ឬ ដំណើរការផ្លូវច្បាប់ទាក់ទងនឹងបទល្មើសដែលពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោល។
   - **ធនាគារដៃគូ** របស់ **ខេប៊ីប្រាសាក់** ស្នើសុំនូវព័ត៌មាន និង/ឬ ឯកសារបន្ថែមពាក់ព័ន្ធក្នុងដំណើរការយកចិត្តទុកដាក់ស្គាល់អតិថិជន។
2. លោក-លោកស្រីយល់ព្រមថា ការបើកបង្ហាញព័ត៌មានដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ នឹងមិនមានន័យថា **ខេប៊ីប្រាសាក់** រំលោភបំពាន ចំពោះច្បាប់ ឬ កាតព្វកិច្ច រក្សាភាពសម្ងាត់ជូនអតិថិជនឡើយ។

## VIII. ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

លោក-លោកស្រីយល់ព្រមឱ្យខេប៊ីប្រាសាក់ ពន្យារពេលទូទាត់ បង្ខាំង ឬ បញ្ឈប់ប្រតិបត្តិការផ្ទេរប្រាក់អន្តរជាតិដែលបានស្នើសុំដោយមិនមានជាប់កាតព្វកិច្ចទទួលខុសត្រូវអ្វីឡើយ ប្រសិនបើ **ខេប៊ីប្រាសាក់** ឬ ធនាគារដៃគូរកឃើញថា៖

- មូលនិធិនៃប្រតិបត្តិការ ឬ គណនីមានទំនាក់ទំនង ឬ ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលចំពោះសកម្មភាពល្មើសច្បាប់ណាមួយក្នុងប្រទេសកម្ពុជា ឬ ច្បាប់អន្តរជាតិ និង
- មានការសង្ស័យចំពោះប្រភពដើមនៃប្រាក់ផ្ទេរនោះ
- មានការបង្គាប់បញ្ជាពីតុលាការ ឬ ពីធនាគារជាតិ នៃ កម្ពុជា។

## IX. សំណងនៃការខូចខាត

1. លោក-លោកស្រី យល់ព្រមក្នុងការទូទាត់សំណងជូន **ខេប៊ីប្រាសាក់** ឬ ធនាគារដៃគូ នូវរាល់កម្រៃជើងសារ ការខូចខាត ការប្តឹងផ្តល់ ការទាមទារសំណង និងចំណាយផ្លូវច្បាប់ផ្សេងៗ ដែលបណ្តាលមកពីការស្នើសុំណាមួយលើសេវាផ្ទេរប្រាក់អន្តរជាតិរបស់លោក-លោកស្រី។
2. លោក-លោកស្រី យល់ព្រមឱ្យខេប៊ីប្រាសាក់កាត់ទឹកប្រាក់ដែលមាននៅក្នុងគណនីរបស់ខ្លួន សម្រាប់ទូទាត់សំណងដែលបានរៀបរាប់ខាងលើនេះទៅតាមស្ថានភាពជាក់ស្តែង។

## X. ផ្សេងៗ

1. លក្ខខណ្ឌនេះអាចធ្វើការកែប្រែជាបន្តបន្ទាប់ដើម្បីឱ្យសមស្របជាមួយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
2. លក្ខខណ្ឌនេះត្រូវបានរៀបចំឡើងជាភាសាខ្មែរ និងភាសាអង់គ្លេស។ ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរមានន័យមិនស្រប ឬ មិនស៊ីគ្នា នោះអត្ថបទជាភាសាខ្មែរចាត់ទុកជាផ្លូវការ។

# Terms and Conditions of Using "International Fund Transfer"

## I. General Term

Terms and Conditions of International Fund Transfer are an agreement between **customers** and **KB PRASAC Bank Plc.** in relation to requesting an International Fund Transfer transaction via branch, KB PRASAC Corporate or KB PRASAC Mobile. If you agree to use this service, it means that you have read, understood and accepted all the terms and conditions of International Fund Transfer.

If you have any questions or are not clear about any point stated in the Terms and Conditions, you may directly call our Call Center at 023/086 999 911 or visit any KB PRASAC branch for further detailed information.

Please read the following terms and conditions carefully and seek any necessary clarification before completing the transaction of International Fund Transfer.

## II. Key Terms

The key terms herein as stated in the Terms and Conditions of International Fund Transfer:

- **"You" or "Your"** : refer to the Customer who requested to use the International Fund Transfer Service of **KB PRASAC**
- **"Terms and Conditions"** : refer to the "Terms and Conditions of Using International Fund Transfer"
- **"The Bank" or "KB PRASAC"** : refer to **KB PRASAC Bank Plc.**
- **"International Fund Transfer"** : refer to the Outward International Fund Transfer and Inward International Fund Transfer between KB PRASAC and Oversea bank via SWIFT.
- **"Financial Relationship"** : refer to the relationships between you and your company or other companies arising from directly or indirectly holding shares.
- **"Relationship (R)"** : refer to the resident transactor/non-resident transactor is a direct investment enterprise (DIE) of a non-resident transactor / resident transactor who has 10% of share ownership in DIE or more than 10%.
- **"Non-Relationship (N)"** : refer to the resident and non-resident transactors who have no share ownership whatsoever or have share ownership less than 10%.
- **"Don't know (DN)"** : refer to not know about any financial relationships.

## III. Customer's Responsibility

1. You must ensure that all information provided to KB PRASAC to request for any transactions of International Fund Transfer is correct and up-to-date.
2. You may check all the information related to the requesting of International Fund Transfer transaction and the related fee clearly before decide to do the transaction.
3. You authorize KB PRASAC to debit from your account for the transfer amount and related fees of using the International Fund Transfer.
4. You understand and accept that **KB PRASAC** will apply its foreign exchange rate to process International Fund Transfer in foreign currency.
5. You are responsible for providing additional information and/or supporting documents regarding the International Fund Transfer if requested and/or required by the bank or the law.
6. You understand that your application at KB PRASAC's branch / KB PRASAC Corporate / KB PRASAC Mobile will be submitted to the bank for reviewing and processing the transaction. The bank will contact you for additional information/documents (If necessary).
7. You are responsible for Local and International law and guarantee that you are acting on your own and/or relatives will be under this terms and conditions.

## IV. KB PRASAC's Responsibility

1. **KB PRASAC** will make transactions of International Fund Transfer in accordance with the information as you requested and provided only.
2. **KB PRASAC** will not be liable for any losses or costs resulting from insufficient or wrong information given or arising from the correspondent bank's error, negligence, delay, inability to make payment or arising from any other cause or reason whatsoever beyond KB PRASAC and its correspondent's control.
3. **KB PRASAC** may choose to use a correspondent bank to give effect to the instructions of the applicant. A correspondent bank may charge a fee for making the payment to the beneficiary, which will either be deducted from the funds paid to the beneficiary. Where a deduction is made, the beneficiary will receive less than the amount specified in your instruction. If the fee is charged by **KB PRASAC**, you agree that this fee will be debited from your account.
4. KB PRASAC may suspend, delay, or reject your request if KB PRASAC found that you did not fulfill the requirement or lack of supporting documents or information on your requested.
5. **KB PRASAC** reserves the right to amend the service fees, limit of transaction and other Terms and Conditions of use of the International Fund Transfer and give notice to the client as required by law.
6. KB PRASAC is not responsible for any taxes, duties and other expenses which might occur in the other countries in relation to the fund transfer.

## V. Request of International Fund Transfer

1. You must notify to **KB PRASAC** for every payment request including request for amendment, investigation, delaying payment, or cancelling funds transfer.
2. You have agreed to compensate to **KB PRASAC** according to **"Indemnity"**.
3. You authorized **KB PRASAC** to debit funds from your account in order to indemnify all claims mentioned above based on the actual situation.
4. In case the International Fund Transfer was rejected or cancelled or returned **KB PRASAC** will return your funds (after settling all other fees) into your account when KB PRASAC received the funds from the correspondent bank. If the returned fund is in foreign currency, **KB PRASAC** will apply its exchange rate based on the date of receiving the fund.

## VI. Fees Charge

1. The fee of International Fund Transfer and other related fees is set by **KB PRASAC.**
2. You authorized **KB PRASAC** to deduct fee from your account in order to make payment on the International Fund Transfer (including fee on amendment, cancellation, and investigation) and any other expenses from your correspondent bank.

## VII. Confidentiality

1. **KB PRASAC** will not disclose your personal information, account details or account transactions to a third party, except the following:
   - **KB PRASAC** requires information for preparing reports or other relevant activities following local and international law.
   - In case there is court order from court or authority use for investigating or legal processing related to crime whether you have been involved directly or indirectly.
   - In case of **KB PRASAC's correspondent** request for information and/or documents for their due diligence.
2. You agree that any disclosure of information as mentioned in the above clause will not mean that **KB PRASAC** is violated to law or material of breach of customer confidential.

## VIII. Anti-Money laundering and Combating the Financing of Terrorism

You authorized KB PRASAC to postpone, block or cancel the funds transfer instruction without incurring any liability if **KB PRASAC** or a correspondent bank has found that:

- Fund is directly or indirectly involved in the proceeds of unlawful conduct.
- Concern about the sources of fund
- There is a court order from court or National Bank of Cambodia (NBC).

## IX. Indemnity

1. You agree to indemnity and compensate to **KB PRASAC** or its correspondent bank against all commission fees, claims, losses, costs or expenses which may incur as a result of processing funds transfer.
2. You agree to authorize KB PRASAC to debit funds from your account in order to indemnity all claims as mentioned above based on the actual situation.

## X. Others

1. These terms and conditions are subject to change frequently in order to comply with Cambodia law.
2. These terms and conditions are made in both Khmer and English. If there is any inconsistency between Khmer and English versions, the terms of Khmer version shall be prevail.